# អនុក្រឹត្យលេខ ៥៧ អនក្រ.បក

## ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមចំនួន ២៩ ២០០ លានរៀល ( ម្ភៃប្រាំបួនពាន់ ពីររយលានរៀល ) ទៅលើឥណទានថវិការបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៩៩៧/១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៨

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

-បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៥ ប្រ.ក.សហវ.ថ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ .**_ ដោយអនុលោមទៅតាមមាត្រា ៥៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែម

www.pheakdeylaw.com

ឥណទានថវិកាចំនួន ២៩ ២០០ លានរៀល ( ម្ភៃប្រាំបួនពាន់ពីររយលានរៀល ) ទៅលើសៀវភៅថវិការបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

មាត្រា ២ .- ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា១ ខាងលើត្រូវបានផ្តល់បន្ថែមទៅជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈនិងផ្គត់ផ្គង់ ) ចំនួន ២៨ ០៨០ លានរៀល និង ជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និង វប្បធម៌ ) ចំនួន ១ ១២០ លានរៀល ដើម្បីធានាចំណាយទូទាត់លើកិច្ចសន្យាខ្ចីទិញទាំង ៥ មុខ ក្នុងនោះរួមមាន សំភារៈឧបករណ៍វិស្វកម្ម ប្រេងឥន្ធនៈ សំភារៈយោធបរិក្ខារ ឱសថ និង សំភារៈបច្ចេកទេស របស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ សងអោយក្រុមហ៊ុន គូ គីមិច ។

មាត្រា ៣ .- ការបែងចែកឥណទានបន្ថែមថ្មីក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៤ .- ឥណទានថវិកាបន្ថែមនេះ ត្រូវរដ្ឋសភាពិនិត្យអនុម័តជាបន្ទាន់ភ្ជាប់ក្នុងច្បាប់ហិរញ្ញវត្ថុ បន្ថែមមួយ ការបើកចំណាយពិសេសនេះត្រូវបានចាប់សព្វគ្រប់ ។

មាត្រា ៥ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

* * *

## អនុក្រឹត្យលេខ ៥៨ អនក្រ.បក

## ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម ចំនួន ៣.៨០០ លានរៀល ( បីពាន់ប្រាំបីរយលានរៀល ) ទៅលើឥណទានថវិការបស់ក្រសួងមហាផ្ទៃ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៥/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

www.pheakdeylaw.com